**ព្រះរាជាណាចក្រកម្ពុជា**
**ជាតិ សាសនា ព្រះមហាក្សត្រ**

**រាជរដ្ឋាភិបាលកម្ពុជា**
**ក្រសួងមហាផ្ទៃ**

លេខ: ០៣៥ សព/ការ

# សេចក្តីប្រកាសព័ត៌មាន
# ស្តីពី ផលប៉ះពាល់លើប្រជាពលរដ្ឋ និងតំបន់ស៊ីវិលកម្ពុជា ដោយអំពើឈ្លានពានរបស់ភាគីថៃ ចាប់ពីម៉ោង១រសៀល រហូតដល់ ម៉ោង៦ល្ងាច ថ្ងៃទី១២ ខែធ្នូ ឆ្នាំ២០២៥

ក្រសួងមហាផ្ទៃ នៃរាជរដ្ឋាភិបាលកម្ពុជា សូមជម្រាបជូនថា **គិតចាប់ពី ម៉ោង១រសៀល រហូតដល់ ម៉ោង៦ល្ងាច ថ្ងៃទី១២ ខែធ្នូ ឆ្នាំ២០២៥**នេះ អំពើឈ្លានពានរំលោភច្បាប់អន្តរជាតិ និងក្បត់បទឈប់បាញ់មកលើដែនអធិបតេយ្យកម្ពុជារបស់ភាគីថៃ ដែលផ្តើមឡើងជាថ្មីកាលពីថ្ងៃទី៧ ខែធ្នូ បានបណ្តាលឱ្យប៉ះពាល់យ៉ាងធ្ងន់ធ្ងរលើសុវត្ថិភាពប្រជាពលរដ្ឋ និងតំបន់ស៊ីវិលកម្ពុជា ដូចខាងក្រោម៖

**១-ករណីពលរដ្ឋស្លាប់ និងរបួស៖** ពុំមានករណីស្លាប់ និងរបួសថ្មីទេ។ ដូច្នេះ គិតមកដល់ពេលនេះ ករណីពលរដ្ឋស្លាប់មានចំនួន១១នាក់ និងរបួសចំនួន៥៥នាក់។

**២-ករណីពលរដ្ឋនៅជំរំសុវត្ថិភាព៖** ក្នុងខេត្តព្រះវិហារ ឧត្តរមានជ័យ បន្ទាយមានជ័យ បាត់ដំបង ពោធិ៍សាត់ និងខេត្តសៀមរាប មានជនភៀសសឹកសរុប **ចំនួន៥៨.៥៥៨គ្រួសារ** (កើន៨.៩១១គ្រួសារ)ស្មើនឹងមនុស្ស **ចំនួន៣៣១.១៥៨នាក់** (កើន២៧.៩៤៥នាក់) ក្នុងនោះមាន**ស្ត្រីចំនួន១៧៨.៧៣៣នាក់ និងកុមារចំនួន៨៤.០៩៤នាក់**។ ករណីនេះ ពុំបានរាប់បញ្ចូលប្រជាពលរដ្ឋស្រុកមណ្ឌលសីមា ខេត្តកោះកុង ជាង១០០នាក់ ដែលបានភៀសខ្លួន ដោយភ័យខ្លាចការបង្ហោះជ្រួនរបស់ភាគីថៃ។

**៣-ករណីបំផ្លិចបំផ្លាញហេដ្ឋារចនាសម្ព័ន្ធរូបវន្តស៊ីវិល៖** តាមការវាយតម្លៃជាបឋម មានផ្ទះសំបែង និងសម្ភារប្រើប្រាស់របស់ប្រជាពលរដ្ឋ អគារក្រុមហ៊ុនឯកជន អគាររដ្ឋបាល សាលារៀន វត្តអារាម ប្រាសាទបុរាណ ផ្លូវថ្នល់ និងអង្គភាពសាធារណៈជាច្រើនកន្លែង បានកំពុងរងការខូចខាតជាបន្តបន្ទាប់ ខណៈសេវាជាមូលដ្ឋាន ដូចជា សេវារដ្ឋបាល សុខាភិបាល និងអប់រំនៅតាមក្រុង ស្រុក ឃុំ-សង្កាត់ ត្រូវបានផ្អាកស្ទើរទាំងស្រុង ដោយសារតែភាគីថៃបង្កើនការវាយប្រហារដោយអាវុធគ្រប់ធុន និងគ្រប់ទម្រង់មកលើតំបន់ស៊ីវិល។

**ក្រសួងមហាផ្ទៃ នៃរាជរដ្ឋាភិបាលកម្ពុជា** ប្រកាសគាំទ្រ និងជឿជាក់យ៉ាងមុតមាំលើយុទ្ធសាស្ត្រការពារជាតិរបស់ **សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន** ប្រធានព្រឹទ្ធសភា និងជាអគ្គកស្តុភារជាន់ខ្ពស់ នៃកងកម្លាំងប្រដាប់អាវុធកម្ពុជា និង **សម្តេចមហាបវរធិបតី ហ៊ុន ម៉ាណែត** នាយករដ្ឋមន្ត្រីដ៏អង់អាចស្វាហាប់ ដែលក្រោមការដឹកនាំបញ្ជាប្រកបដោយយុទ្ធសាស្ត្រ របស់ **សម្តេច** ទាំងទ្វេ កម្លាំងកងយោធពលខេមរភូមិន្ទ និងនគរបាលការពារព្រំដែននៃក្រសួងមហាផ្ទៃ បានកំពុងប្រកៀកស្មារួមគ្នាការពារបូរណភាពទឹកដី និងអធិបតេយ្យភាពជាតិ ដោយម្ចាស់ការ អង់អាចក្លាហាន ឈរជើងយ៉ាងរឹងមាំ និងមានប្រៀបឈ្នះគ្រប់គោលដៅនៃសមរភូមិប្រយុទ្ធ។/.

ថ្ងៃ សុក្រ ៧រោច ខែ មិគសិរ ឆ្នាំម្សាញ់ សប្តស័ក ព.ស.២៥៦៩
រាជធានីភ្នំពេញ ថ្ងៃទី១២ ខែ ធ្នូ ឆ្នាំ២០២៥

*Unofficial Translation*

**Press Release**

**The Impacts on Civilian Areas, and Casualties Caused by Thailand's Aggression on Cambodia's Sovereign Territory From 1:00PM until 6:00PM, 12 December 2025**

**The Ministry of Interior of the Royal Government of Cambodia** would like to inform the national and international community that, from 1:00pm until 6:00pm on 12 December 2025, the violation of international law and breach of the ceasefire by the Thai side against Cambodia's sovereign territory since 7 December - has caused severe impacts on the safety of civilians, and civilian areas as follows:

1. **Deaths and Injuries**: As of 6:00pm on 12 December 2025, the total number of Cambodian civilians killed has reached 11, and the number of injured has reached 59. **(There are no new figures currently.)**
2. **Displacement of Civilians:** In the provinces of Preah Vihear, Oddar Meanchey, Banteay Meanchey, Battambang, Pursat, and Siem Reap, there are a total of **98,598 displaced families** (increased by 8,911 families), equivalent to **331,158 people** (increased by 27,945 people). Among them are 178,733 women and 84,094 children. This figure does not include more than 100 residents of Mondol Seima district, Koh Kong province, who fled due to fear of Thai drone flights.
3. **Destruction of Civilian Infrastructure and Disruption of Public Services**: According to initial assessments, numerous civilian homes and personal belongings, private company buildings, administrative offices, schools, pagodas, ancient temples, roads, and various public facilities have continued to sustain damage. Meanwhile, essential public services—such as administrative services, healthcare, and education across cities, districts, and communes (sangkats)—have been almost entirely suspended due to Thailand's intensified attacks using all types and forms of weapons against civilian areas.

**The Ministry of Interior of the Royal Government of Cambodia** once again firmly reiterates its full support and unwavering confidence in **Samdech Akka Moha Sena Padei Techo Hun Sen**, President of the Senate and Senior Logistic Commander of the Royal Cambodian Armed Forces, and **Samdech Moha Borvor Thipadei Hun Manet**, the courageous and capable Prime Minister of Cambodia. Under the strategic leadership and experienced guidance of **Samdech Techo** and **Samdech Thipadei**, the forces of the Royal Cambodian Armed Forces and the Border Protection Police of the Ministry of Interior are jointly standing guard to defend the territorial integrity and national sovereignty with discipline, bravery, and determination, standing firmly and successfully achieving every objective on the battlefield.

Phnom Penh, December 12, 2025